# សាលារៀននិងអំពើសម្លាប់ឃោឃៅ
**School Associated Violent Deaths**

អំពើឃោរឃៅបាញ់សម្លាប់សិស្សនៅក្នុងបរិវេណសាលារៀន ជាអំពើមួយដែលគួរឲ្យអាណោចអធម្ម ហើយដែលធ្វើឲ្យមាតាបិតាជាច្រើន មានការបារម្ភជានិច្ច ចំពោះសន្តិសុខរបស់កូន ពេលទៅរៀនរាល់ថ្ងៃ។ ប៉ុន្តែទោះបី ជាមានហេតុការណ៍ទាំងនេះ កើតឡើងនៅ រដ្ឋ Colorado និង Wisconsin, ហើយ ក្នុងពេលថ្មីៗ រដ្ឋ Pennsylvania យ៉ាងណាក៏ដោយ ក៏បរិវេណសាលារៀន នៅតែជាកន្លែងមួយ ដែលមានសន្តិសុខគ្រប់គ្រាន់សំរាប់សិស្សទាំងអស់ដែរ។ តាមការពិតទៅ ការស្លាប់បាត់បង់ជីវិតរបស់ក្មេងៗ ភាគច្រើន គឺមាននៅក្រៅសាលានិងក្រៅពេលម៉ោងរៀន ទៅវិញទេ។

ដើម្បីឲ្យបានយល់ច្បាស់អំពីមូលហេតុនិងវិធីការពារក្មេងៗ ឲ្យជៀសផុតពីគ្រោះថ្នាក់ទាំងនេះ មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ (Center for Disease Control and Prevention) បានធ្វើការសិក្សាវិភាគ អំពីទំនាក់ទំនងរវាងអំពើឃោរឃៅ នៅតាមសាលារៀន និងការដែលក្មេងស្លាប់បាត់បង់ជីវិត។ លំដាប់តទៅនេះ ជាពត៌មានខ្លះៗ ដែលគួរជ្រាប៖

មកទល់នឹងពេលនេះ មជ្ឈមណ្ឌល CDC បានរកឃើញថា៖

- ចំនួនក្មេងដែលស្លាប់បាត់បង់ជីវិត ទាក់ទងទៅនឹងសាលារៀន គឺមានចំនួនតែ 1 % នៃចំនួនក្មេងដែលស្លាប់ទាំងអស់ក្នុងសហរដ្ឋ តែប៉ុណ្ណោះ។
- ការស្លាប់បាត់បង់ជីវិត នៅក្នុងសាលារៀន ភាគច្រើន ច្រើនកើតឡើង នៅចន្លោះវេណនីមួយៗ ដូចជា ពេលចូលរៀន ឬពេលចេញពីរៀន, ឬ ពេលសិស្សទទួលទានអាហារ (Lunch time)។
- ការស្រាវជ្រាវនេះ បានឲ្យដឹង ម្យ៉ាងទៀតថា ការបាញ់សម្លាប់សិស្សក្នុងសាលា ក៏ច្រើនមាននៅពេលសាលារៀន ចាប់ផ្តើមចូលរៀន មុនដំបូង បន្ទាប់ពេលពីវិស្សមកាល (វ៉ាកង)។
- ជនឧក្រិដ្ឋ ដែលអាចមានរួមទាំងសិស្សតូចៗ, សិស្សធំៗ, និងមនុស្សពេញវ័យ, ចំនួន 50% ច្រើនបញ្ចេញជាសញ្ញា ឬតម្រុយអ្វីមួយ ដែលអាចឲ្យដឹងជាមុនបាន។ សញ្ញាទាំងនេះ មានដូចជា ការសំឡុតគំរាមកំហែង, ឬការសរសេរពាក្យទាំងនោះលើក្រដាស់អ្វីមួយ ជាដើម មុនពេលចាប់ផ្តើមប្រព្រឹត្ត។
- ក្នុងចំណោមសិស្សដែលប្រព្រឹត្តអំពើឃោរឃៅ នៅក្នុងសាលារៀន, ចំនួន 20% ច្រើនខ្លួនឯង ជាសិស្សដែលធ្លាប់រងគ្រោះ ដោយសារសិស្សឯទៀតធ្វើបាប ឬលេង។

ដើម្បីការពារនូវអំពើឃោរឃៅក្នុងសាលរៀន មជ្ឈមណ្ឌល CDC បានធ្វើសហការណ៍ យ៉ាងជិតស្និត ជាមួយក្រសួងអប់រំជាតិនិងក្រសួងតុលាការ និងប្រមែប្រមូលពត៌មានទាំងឡាយដែលទាក់ទងទៅនឹងអំពើឃោរឃៅសម្លាប់សិស្ស ដើម្បីសិក្សាអំពីប្រភេទនិងប្រភព នៃអំពើទាំងនោះ ហើយជួយសាលារៀនទាំងអស់ ឲ្យបង្កើតជាគំរោងការណ៍ សំរាប់ការពារ កុំឲ្យមានហេតុការណ៍ទាំងនោះ កើតមានបានតទៅទៀត។ គំរោងការណ៍ទាំងនេះ មាន ដូចជា៖

- ចាត់ឲ្យមានគ្រូត្រួតពិនិត្យនិងបង្កើតជាគំរោងការណ៍ក្នុងសាលារៀន ដោះស្រាយជំលោះផ្សេងៗ ដើម្បីកុំឲ្យសិស្សទាំងនោះជ្រុលដៃទាន់ នាំឲ្យមានគ្រោះថ្នាក់ ថ្លោះធ្លោយ។
- យកចិត្តទុកដាក់ ស្តាប់ពាក្យគំរាមកំហែងរបស់សិស្សឲ្យមែនទែន។ ហើយអនុញ្ញាតិឲ្យសិស្សនោះ ពិភាក្សាជាមួយនរណាម្នាក់ទៀត ដើម្បីកាត់បន្ថយកំហឹងផ្សេងៗ។ ម្យ៉ាងទៀត ទាក់ទងឲ្យឪពុកម្តាយដឹងជាមុន ដើម្បីឲ្យឪពុកម្តាយជួយចាត់វិធានការណ៍ការពារគ្រោះថ្នាក់ ដែលអាចកើតមានឡើង។
- បង្កើតកម្មវិធីការពារអំពើឃោរឃៅ ដែលអាចជួយឲ្យគ្រូបង្រៀននិងបុគ្គលិកសាលារៀនដឹងអំពីសញ្ញានៃគ្រោះថ្នាក់ មុនពេលដែលគ្រោះថ្នាក់នោះ ចាប់មានជ្រុលហួសក៏រិត។

នៅពេលក្មេងមើលទូរទស្សន គេអាចឃើញការបាញ់សម្លាប់នៅសាលរៀនក្នុងរដ្ឋឯទៀតហើយអាចមានការព្រួយបារម្ភ ឬភ័យខ្លាចក្រែង ហេតុការណ៍ទាំងនោះ មាននៅសាលារៀនរបស់ខ្លួន នៅពេលនោះ ក្នុងឋានៈជា មាតាបិតា លោកអ្នកអាច ឆ្លៀតឱកាស ស្តាប់ការព្រួយបារម្ភរបស់កូន ដោយកុំប្រងើយកន្តើយ ហើយបញ្ជាក់ឲ្យកូនដឹងច្បាស់ថា លោកអ្នកយល់ច្បាស់អំពីទុក្ខធុរៈទាំងនោះ។ ក្មេងៗ អាចបញ្ចេញអារម្មណ៍ប្លែកៗគ្នា ទៅតាមអាយុរបស់គ្នារៀងៗខ្លួន។ ឧទាហរណ៍ ក្មេងតូចៗ ច្រើនបញ្ចេញអារម្មណ៍របស់ខ្លួន ដោយការលេង ឬដោយការគូររូបគំនូរ។ រីឯក្មេងជំទង់វិញ អាចមានលទ្ធភាពនឹងបញ្ចេញអារម្មណ៍របស់ខ្លួនដោយសារការពិគ្រោះ ពិភាក្សានិងនិយាយស្តី។ ក្នុងលក្ខណៈនេះ យោលទៅតាមបណ្ឌិតផ្នែកចិត្តសាស្រ្ត (Psychologist) មាតាបិតា គួរប្រាប់កូនឲ្យច្បាស់ថា មានបុគ្គលិកនៅសាលារៀន, អញ្ញាធរ, និងប៉ូលិសជាច្រើន បានខំធ្វើសហការណ៍ ជាមួយគ្នា ដើម្បីការពាររក្សាសន្តិសុខនិងទប់ទល់ កុំឲ្យអំពើឃោរឃៅកើតមាននៅសាលារៀននោះ។

ចំពោះពត៌មានបន្ថែមស្តីអំពីស្ថិតិ, វិធីការពារសន្តិសុខក្នុងសាលារៀន សូមអានវិបសៃរបស់មជ្ឈមណ្ឌលការពារនិងបង្រ្កាបជម្ងឺ (Center for Disease Control and Prevention) អាសយដ្ឋាន www.cdc.gov ។

ពត៌មាននេះដកស្រង់និងបកប្រែចេញពីពត៌មាននៃ មជ្ឈមណ្ឌលការពារនិងបង្ក្រាបជម្ងឺ (Center for Disease Control and Prevention) ដោយមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល។